**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៩......សសរ

# សេចក្តីសំរេច

## ស្តីពីការផ្ទេរចនាសម្ព័ន្ធគ្រប់គ្រងស្ថានីយ៍វិទ្យុ

## អេហ្វ អឹមជាតិកម្ពុជា ៩៦ មេហ្គាហឺត

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម /០១៩៦ / ១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ . បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១** : ផ្ទេរចនាសម្ព័ន្ធគ្រប់គ្រងស្ថានីយ៍វិទ្យុអេហ្វ អឹមជាតិកម្ពុជា ៩៦ មេហ្គាហឺត បច្ចុប្បន្នស្ថិតក្រោមឱវាទផ្ទាល់ជាបណ្តោះអាសន្នរបស់ទីស្តីការក្រសួងពត៌មាន អោយមកស្ថិតក្រោមឱវាទផ្ទាល់របស់អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា នៃក្រសួងពត៌មានវិញ ។

**ប្រការ ២** : សេចក្តីសំរេចរបស់ក្រសួងពត៌មាន លេខ ០០៧៨-៩៩ ព.ម ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតនាយកដ្ឋានវិទ្យុអេហ្វអឹមជាតិកម្ពុជា នៃក្រសួងពត៌មាន និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ .... មិថុនា ឆ្នាំ ២០០៣*

<u>កន្លែងទទួល</u> :

*- ក្រសួងព្រះបរមរាជវាំង*
*- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*- អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*- ដូចប្រការ ៣*
*- ឯកសារ- កាលប្បវត្តិ*

**ហ៊ុន សែន**